**MEDIA STATEMENT**

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

សម្រាប់ទិវាអន្តរជាតិ ដើម្បីបំបាត់ការរើសអើងពូជសាសន៍
ថ្ងៃសៅរ៍ទី២១ ខែមីនា ឆ្នាំ២០១៥

# ការយល់ដឹងអំពីសោកនាដកម្មជាប្រវត្តិសាស្ត្រ គឺជាគន្លឹះក្នុងការពង្រឹង ការប្រយុទ្ធជាអន្តរជាតិ ប្រឆាំងនឹងជាតិសាសន៍និយម

ទីក្រុងហ្សឺណែវ (២០ មីនា ២០១៥) - *ថ្លែងនៅមុនពេលនៃទិវាអន្តរជាតិ ដើម្បីលុបបំបាត់ការរើសអើងពូជសាសន៍ ជំនាញការបីរូបរបស់អង្គការសហប្រជាជាតិខាងជាតិសាសន៍និយម បានអំពាវនាវឲ្យរដ្ឋាភិបាលនានានៅជុំវិញពិភពលោក រក្សាឲ្យមានការចងចាំជាប្រវត្តិសាស្ត្រ អំពីឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងក្នុងអតីតកាល ដើម្បីធ្វើឲ្យការប្រយុទ្ធជាអន្តរជាតិ ប្រឆាំងនឹងជាតិសាសន៍និយម កាន់តែមានប្រសិទ្ធភាពថែមទៀត។*

*អ្នករាយការណ៍ពិសេសស្តីពីទម្រង់សហសម័យនៃជាតិសាសន៍និយម លោក ម៉ូតាម៉ា រ៉ូតេ (Mutuma Ruteere) ប្រធានអ្នករាយការណ៍នៃក្រុមការងារជំនាញការស្តីពីប្រជាជនដែលមានដើមកំណើតអាហ្វ្រិក លោក មីរីល ហ្វាណុង ម៉ង់ដេស ហ្វ្រង់ (Mireille Fanon Mendes- France) និងប្រធានគណៈកម្មាធិការទទួលបន្ទុកការបំបាត់ការរើសអើងពូជសាសន៍ លោក ជូសេ ហ្វ្រង់ស៊ីស្កូ កាលី តៃ្យ (José Francisco Cali Tzay ) បានមានប្រសាសន៍ថា ការបញ្ចប់សោកនាដកម្មសិទ្ធិមនុស្សដែលមានពីអតីតកាលកុំឲ្យមានបន្តទៅទៀត អាចនឹងសម្រេចទៅបាន លុះត្រាណាតែធ្វើតាមរយៈឆន្ទៈនយោបាយ និងការអប់រំ។*

"ឆ្នាំនេះ ទិវាអន្តរជាតិ សម្រាប់ការបំបាត់ការរើសអើងពូជសាសន៍ មានសម្លេងឮខ្ទរខ្ទារជាពិសេស នៅពេលដែលយើងប្រារព្ធខួបលើកទី៥0 នៃអនុសញ្ញាអន្តរជាតិ ស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD) និងចាប់ផ្តើមទំព័រទសវត្សរ៍អន្តរជាតិ សម្រាប់ប្រជាជនដែលមានដើមកំណើតអាហ្វ្រិក (ឆ្នាំ២០១៥-២០២៤)។

ទន្ទឹមនឹងមានការតស៊ូពុះពារ ដើម្បីឲ្យពិភពលោកមួយចាកផុតពីជាតិសាសន៍និយម និងការរើសអើងពូជសាសន៍ យើងក៏ត្រូវចងចាំផងដែរអំពីសោកនាដកម្មជាប្រវត្តិសាស្ត្រ និងអំពើអមនុស្សធម៌ ដែលទាក់ទងទៅនឹងការចាត់ជាឋានានុក្រមពូជសាសន៍ ឬជាតិពន្ធុ និងការរើសអើង ដែលបានធ្វើឲ្យប៉ះពាល់ដល់ប្រវត្តិសាស្ត្រពិភពលោក និងបានបណ្តាលឲ្យមានទុក្ខវេទនាមិនអាចរៀបរាប់អស់ ដែលការប្រយុទ្ធប្រឆាំងនឹងជាតិសាសន៍និយមនេះគឺជាភារកិច្ចរួមរបស់យើងទាំងអស់គ្នាដែលមិនអាចញែកដាច់ពីគ្នា ហើយដែលតួអង្គទាំងអស់ត្រូវសន្យាអនុវត្តឲ្យបាន។ យើងនៅតែបន្តប្រឈមជាមួយនឹងភស្តុតាងដែលថា យើងនៅតែមានឧបសគ្គមួយចំនួន ក្នុងការធ្វើឲ្យសម្រេច

គោលដៅនៃការមិនរើសអើងជាសកល សុខដុមនីយកម្មអន្តរជាតិពន្ធុ និងយុត្តិធម៌មិនលំអៀង ដែលមនុស្សជាច្រើនបាននិងកំពុងខិតខំធ្វើឲ្យសម្រេចគោលដៅនេះ។

ចំណងចាក់ស្រេះរវាងទម្រង់សហសម័យ និងទម្រង់អតីតកាលនៃការរើសអើងពូជសាសន៍ ជាការពិតណាស់ ត្រូវតែបានធ្វើការពិចារណា ដើម្បីបង្ការទប់ស្កាត់ការរើសអើងពូជសាសន៍ ការស្អប់ខ្ពើមជនបរទេស ការស្អប់ខ្ពើមប្រជាជនដែលមានដើមកំណើតអាហ្វ្រិកស្បែកខ្មៅ និងការមិនអត់ឱនដែលពាក់ព័ន្ធផ្សេងទៀត និងធ្វើឲ្យពូជសាសន៍និយមរលាយបាត់ពីសង្គមរបស់យើង។ ក្នុងន័យនេះ ឆន្ទៈនយោបាយ និងការអប់រំ គឺជាគន្លឹះក្នុងការបញ្ចប់សោកនាដកម្មសិទ្ធិមនុស្សដែលមានពីអតីតកាលកុំឲ្យមានបន្តទៅទៀត។

ជារឿយៗ សៀវភៅប្រវត្តិសាស្ត្រ ហាក់នៅស្ងៀមស្ងាត់អំពីអំពើសាហាវយង់ឃ្នងក្នុងអតីតកាល ដែលបានប្រព្រឹត្តក្រោមហេតុផលពូជសាសន៍ និងជាតិពន្ធុ បំភ័ន្ត ឬបំភ្លៃការពិតជាប្រវត្តិសាស្ត្រ សាបព្រោះការប្រកាន់ពូជសាសន៍និងគេចវេសពីប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី និងការរួមចំណែកជាវិជ្ជមានរបស់អ្នកទាំងឡាយដែលរងផលប៉ះពាល់ដោយសារពូជសាសន៍និយម និងការរើសអើង រាប់ទាំងប្រជាជនដែលមានដើមកំណើតអាហ្វ្រិក ជនភាគតិចទេសន្តរប្រវេសន៍ ជនជាតិដើមភាគតិច និងក្រុមដទៃទៀត។

នៅពេលដែលយើងរំលឹកព្រឹត្តិការណ៍ដ៏សំខាន់នេះ សម្រាប់អនុសញ្ញាអន្តរជាតិ ស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍(ICERD) យើងអាចងាកក្រោយក្រឡេកមើលជ័យជំនះដ៏អស្ចារ្យមួយចំនួន ក្នុងការប្រយុទ្ធប្រឆាំងនឹងពូជសាសន៍និយម ដែលជោគជ័យដ៏មហាធំធេងបំផុតនោះគឺ ការបញ្ចប់របបអាផាថេត នៅអាហ្វ្រិកខាងត្បូង។ ប៉ុន្តែ ពូជសាសន៍និយម និងការរើសអើងពូជសាសន៍ នៅតែមានវត្តមាននាពេលបច្ចុប្បន្ននេះ នៅក្នុងសង្គមសម័យទំនើបរបស់យើងនៅទូទាំងពិភពលោក ហើយពូជសាសន៍និយម និងការរើសអើងពូជសាសន៍នេះស្ថិតក្នុងទម្រង់ផ្សេងៗគ្នាជាច្រើន។ គ្រាន់តែដោយសារការទទួលស្គាល់ និងការយល់ដឹងអំពីប្រវត្តិសាស្ត្រប៉ុណ្ណឹង តើអាចឲ្យយើងធ្វើឲ្យជ័យជំនះក្នុងអតីតកាល ក្លាយជាការពិតមួយនៅក្នុងសហសម័យបានដែរឬយ៉ាងណា។

យើងអំពាវនាវដល់រដ្ឋនានា និងតួអង្គពាក់ព័ន្ធទាំងអស់ ឲ្យអនុម័ត និងអនុវត្តវិធានការផ្សេងៗ ដើម្បីរក្សាឲ្យមានការចងចាំជាប្រវត្តិសាស្ត្រអំពីឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅក្នុងអតីតកាល ដើម្បីបំផុសការត្រិះរិះពិចារណាឲ្យបានត្រឹមត្រូវអំពីហេតុការណ៍ជាប្រវត្តិសាស្ត្រទាក់ទងនឹងអំពើសាហាវឃោរឃៅក្នុងអតីតកាល នៅក្នុងសៀវភៅអត្ថបទ និងឯកសារអប់រំផ្សេងទៀត ដើម្បីអនុវត្តគំនិតផ្តួចផ្តើមលើកកម្ពស់ការយល់ដឹង និងធានាឲ្យមានការបណ្តុះបណ្តាលដល់គ្រូបង្រៀន អំពីការរើសអើងពូជសាសន៍ ចងក្រងបោះពុម្ពសៀវភៅសិក្សាដោយមិនលំអៀងដែលរួមបញ្ចូលការរួមចំណែកវិជ្ជមានពីជនរងគ្រោះដោយការរើសអើងពូជសាសន៍ ទន្ទឹមនេះដែរ ត្រូវលើកកម្ពស់ថែមទៀតនូវការអត់ឱនឲ្យគ្នាទៅវិញទៅមក និងការគោរពចំពោះចម្រុះភាព។

យើងជម្រុញឲ្យរដ្ឋនានា អនុវត្តឲ្យបានពេញលេញនូវអនុសញ្ញាអន្តរជាតិ ស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD) ក៏ដូចជាសេចក្តីប្រកាស និងកម្មវិធីសកម្មភាពទីក្រុងឌូបាន និងកម្មវិធីសកម្មភាពសម្រាប់អនុវត្តទសវត្សរ៍អន្តរជាតិ សម្រាប់ប្រជាជនដែលមានដើមកំណើតអាហ្វ្រិក៖ ការទទួលស្គាល់ យុត្តិធម៌ និងការអភិវឌ្ឍ បង្កើតបានជាឧបករណ៍ដ៏សំខាន់ ក្នុងការប្រយុទ្ធជាអន្តរជាតិប្រឆាំងនឹងពូជសាសន៍និយម រួមទាំងអំពើសាហាវយង់ឃ្នងក្នុងអតីតកាលផងដែរ˝ ។

ចប់

*លោក ម៉ូតាម៉ា រ៉ូតេ (Mr. Mutuma Ruteere) (ជនជាតិកេនយ៉ា) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្សតែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីទម្រង់សហសម័យនៃជាតិសាសន៍និយម ការរើសអើងពូជសាសន៍ ការស្អប់ខ្ពើមជនបរទេស និងការមិនអត់ឱនដែលពាក់ព័ន្ធផ្សេងទៀត ក្នុងខែវិច្ឆិកា ឆ្នាំ២០១១។ ដើម្បីស្វែងយល់បន្ថែមទៀត សូមចូលទៅកាន់គេហទំព័រ៖*
*http://www.ohchr.org/EN /Issues/Racism/SRRacism/Pages/IndexSRRacism.aspx*

*សំរាប់ព័ត៌មានបន្ថែម និងការស្នើសុំព័ត៌មាន សូមទាក់ទងមក៖*
*កែលលី សាន់ដ្រា អហ្គនីមបា (Kelly-Shandra Ognimba) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩២ ៦៨ / ឬតាមរយៈអ៊ីម៉ែល kognimba@ohchr.org) ឬ ធារី ដែលប្រាដូ (Thierry del Prado) (+៤១ ៩១៧ ៩២ ២២ ៣២ / ឬតាមរយៈអ៊ីម៉ែល tdelprado@ohchr.org)*

*ក្រុមការងារនៃជំនាញការស្តីពីប្រជាជនដែលមានដើមកំណើតអាហ្វ្រិក ត្រូវបានបង្កើតឡើងដោយអតីតគណៈកម្មការសិទ្ធិមនុស្ស ក្នុងឆ្នាំ២០០២ បន្ទាប់ពីមានសន្និសីទពិភពលោកប្រឆាំងនឹងជាតិសាសន៍និយម ដែលបានប្រារព្ធឡើងនៅទីក្រុងឌូបាន ក្នុងឆ្នាំ២០០១។ ដើម្បីស្វែងយល់បន្ថែមទៀត សូមចូលទៅកាន់គេហទំព័រ៖*
*http://www.ohchr.org/EN/Issues/Racism/WGAfricanDescent/Pages/WGEPADIndex.aspx*
*សំរាប់ព័ត៌មានបន្ថែម និងការស្នើសុំព័ត៌មាន សូមទាក់ទងមក គ្រីស្ទីណា សោនឌឺរស៍ (Christina Saunders) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩១៩៧ / ឬតាមរយៈអ៊ីម៉ែល csaunders@ohchr.org) ឬសរសេរទៅកាន់ africandescent@ohchr.org*

*គណៈកម្មាធិការស្តីពីការបំបាត់ការរើសអើងពូជសាសន៍ (CERD) គឺជាស្ថាប័នមួយដែលមានជំនាញការឯករាជ្យ ដែលមានភារកិច្ចឃ្លាំមើលការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ដោយរដ្ឋភាគីរបស់ខ្លួន។ ដើម្បីស្វែងយល់បន្ថែមទៀត សូមចូលទៅកាន់គេហទំព័រ៖*
*http://www.ohchr.org/EN/HRBodies/CERD/Pages/CERDIndex.aspx*

*សំរាប់ព័ត៌មានបន្ថែម និងការស្នើសុំព័ត៌មាន សូមទាក់ទងមក ហ្គាប្រ៊ីលឡា ហាបធំ (Gabriella Habtom) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩១៩៣ / ឬតាមរយៈអ៊ីម៉ែល ghabtom@ohchr.org) ឬសរសេរទៅកាន់ cerd@ohchr.org*

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងតាមរយៈបណ្តាញព័ត៌មានសង្គម៖**
**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights
**ទ្វីតធឺ៖** http://twitter.com/UNrightswire
**ហ្គោហ្គល៖** Google+ gplus.to/unitednationshumanrights
**យូធូប៖** http://www.youtube.com/UNOHCHR
**ផែនមើលលិបិក្រមសិទ្ធិមនុស្សជាសកល៖** http://uhri.ohchr.org/en